# ការសំភាសន៍របស់មីង កង សុខា

ក៖ អ្នកធ្វើការសំភាសន៍ហួន ឡាយហុក ខ៖ អ្នកដែលត្រូវគេសំភាសន៍កង សុខា

ក៖ជាដំបូងសូមអនុញ្ញាតជំរាបសួរមីដែលបានអោយញុំសំភាសន៍ថ្ងៃនេះ ហើយថ្ងៃនេះជាថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១៧។ ហើយការសំភាសន៍រៀបចំដោយសាកលវិទ្យាល័យ**Brigham Young University**ដោយហៅកាត់ថា**BYU**។អញ្ចឹងញុំសូមអនុញ្ញាតសំភាសន៍មីងបានទេមីង ហើយអនុញ្ញាតសំលេងមួយនេះទៅចាក់ផ្សាយនៅគេហទំព័ររបស់លសាកលវិទ្យាល័យBrigham YoungដោយហៅគាតថាCambodianoralhistories.byu.edu បាត!
អញ្ចឹងសូមណែនាំឈ្មោះមីង។

ខ៖ខ្ញុំឈ្មោះសុខា។

ក៖ចុះឈ្មោះពេញអីគេមីង។

ខ៖ឈ្មោះពេញ កង សុខា។

ក៖អញ្ចឹងណំ មានឈ្មោះហៅក្រៅទេ។

ខ៖អត់មានទេ។

ក៖ហើយចុះប្ដីមីងមានឈ្មោះអីគេដែល។

ខ៖ឈ្មោះគៀវ ហេង។

ក៖អញ្ចឹងមីងសព្វថ្ងៃបែកបាកគ្រួសារហើយ។

ខ៖ចាំ បែកបាក់យូរហើយ។

ក៖បាទ! ដោយសារតែនៅជាមួយគ្នាអត់ចុះសម្រុងគ្នា ណោះមីងណោះ។

ខ៖ចាំ។

ក៖ហើយចុះពេលដែលមីងការជាមួយគាត់អ្ហ៎ះ
មីងរៀបការដោយម៉ែឪរៀបចំអោយរឺមីងរៀបការដោយចិត្តឯង។

ខ៖ម៉ែឪបងប្អូន គាត់បែកពីអាពូតមកគាត់អត់មានម៉ែឪគាត់មានតែបងប្អូនគាត់។

ក៖ចុះពេលដែលការគាត់មានអោយថ្លៃជំនួនមីងទេរឺក៏ម៉េចដែរ។

ខ៖កាលជំនាន់នឹងយើងគ្មាននេះទេ យើងបែកនេះ យើងចេញគ្នាបន្តិចបន្តួច។

ក៖កាលនឹងគាត់អោយអីគេ។

ខ៖កាប់គោ កាប់ជ្រូកការនឹង ដែលយើងចិញ្ចឹមអីការទៅណា។

ក៖បាទ! ចុះអញ្ចឹងមីងអាយុប៉ុន្មានហើយមីង។

ខ៖ខ្ញុំអាយុ៦១ហើយ។

ក៖មីងកើតឆ្នាំអីគេ?

ខ៖ឆ្នាំចរ។

ក៖ឆ្នាំចរ ៦១។ចុះមីងឆ្នាំ១០០០ប៉ុន្មាន?

ខ៖ឆ្នាំ១០៥៧។

ក៖ហើយភូមិកំណើតមីងនៅណាដែល ស្រុកកំណើតអ្នុះ។

ខ៖ខ្ញុំនៅការរាស់ថ្មគោលនេះផ្លូវត្រីនេះ ទៅខាងល្វាហែម។

ក៖មីងអាចប្រាប់ភូមិឃុំស្រុកអីអញ្ចឹងអ្នុះ។

ខ៖ខ្ញុំចេញយូរហើយមិនដឹងភូមិអីទេ ខ្ញុំដឹងនៅភូមិថ្មគោលអញ្ចឹងអ្នុះ ស្រុកល្វាហែម ឃុំអីញ៉ាំអត់បានដឹងទេព្រោះនៅភ្នំពេញយូរហើយ។

ក៖ចុះនៅខេត្តអីគេមីង?

ខ៖នៅខេត្តកណ្តាលយើងនឹង។

ក៖ចុះពេលមីងការហើយមីងនៅជាមួយម្តាយមីងរឺក៏នៅផ្ទះផ្សេង។

ខ៖នៅផ្ទះបង។

ក៖បងឈ្មោះអីគេ?

ខ៖បងខ្ញុំស្លាប់បាត់ហើយ។

ក៖អញ្ចឹងញ៉ាំសុំស្គាល់ឈ្មោះម្តាយឪពុកមីង កាត់ឈ្មោះអីគេ។

ខ៖ម្តាយខ្ញុំឈ្មោះយឹម។

ក៖ឈ្មោះយឹម កាលគាត់ស្លាប់គាត់អាយុប៉ុន្មាន?

ខ៖គាត់ស្លាប់តាំងពីឆ្នាំ១០៦៨។

ក៖កាលនឹងគាត់កើតអីបានស្លាប់មីង។

ខ៖គាត់កើតជំងឺមហារីក។

ក៖គាត់កើតជំងឺមហារីក ហើយចុះឪពុកមីង។

ខ៖ឪពុកខ្ញុំនៅរស់សព្វថ្ងៃ។

ក៖នៅរស់គាត់ឈ្មោះអីគេ។

ខ៖គាត់ឈ្មោះកង ក្លឹង។

ក៖គាត់អាយុប៉ុន្មានដែលមីង។

ខ៖៨៤៨៥ហើយ។

ក៖អ៎ អញ្ចឹងឥលូវគាត់រកការងារអីគេ។

ខ៖គាត់នៅតែផ្ទះគាត់អត់ធ្វើអីទេ គាត់ចាស់ហើយនឹង
គាត់ចាស់ហើយមានតែកូនចៅចិញ្ចឹម។

ក៖ចុះមីងមានស្គាល់យីទួតតាទួតគាត់ឈ្មោះអីគេ។

ខ៖យីទួតតាទួតអត់ស្គាល់ទេ កើតមកមិនទាន់ ទាន់តែជីដូន។

ក៖អញ្ចឹង ជីដូនគាត់ឈ្មោះអីគេអញ្ចឹង។

ខ៖គាត់ឈ្មោះយីពុយ។

ក៖ចុះជីតា។

ខ៖តាទិត តាទិតយីពុយ បើថាជីទួតអត់ទាន់ទេ ទាន់តែតាជីដូនគាត់កើតនឹង។

ក៖ចុះជីតា គាត់ប្រកបមុខរបបរអីគេដែល។

ខ៖គាត់ធ្វើចំការនៅម្តុំគៀនស្វាយយើងនឹង គាត់មានចំការដាំស្វាយ ដាំពូត
ដាំសណ្តែកអីអញ្ចឹង គាត់អត់មានធ្វើការអីទេ។

ក៖ចុះអី ម្តាយឪពុករបស់មីងពីមុនគាត់ធ្វើអីគេ។

ខ៖ម្តាយឪពុកខ្ញុំ ពីមុខគាត់ជាងច្នៃត្បូង។

ក៖អ៎ ជាងច្នៃត្បូងនៅប៉ៃលិនមែន?

ខ៖ជាងច្នៃត្បូងនៅភ្នំពេញយើងនឹង។

ក៖អ៎ នៅភ្នំពេញ ហើយចុះមីងមានកូនប៉ុន្មានអ្នកហើយមីង។

ខ៖ខ្ញុំមានកូន២នាក់។

ក៖កូនបងឈ្មោះអីគេ?

ខ៖កូនបងឈ្មោះរេត សុផារ៉ា។

ក៖ហើយគាត់អាយុប៉ុន្មានហើយ។

ខ៖អាយុ៣៣ហើយ។

ក៖ហើយចុះគាត់មានគ្រួសារនៅមីង។

ខ៖កាត់មានគ្រួសារហើយ។

ក៖មានហើយ
ចុះមីងមានដឹងថាគាត់ការមីងជាអ្នកផ្សំផ្គុំអោយរឺក៏ការដោយខ្លួនឯងអញ្ចឹងអ្ហ៎ះ។

ខ៖វាស្រលាញ់ខ្លួនឯង។

ក៖គាត់ស្រលាញ់ខ្លួនឯងណ៎ ហើយម៉ែឪក៏ផ្សំផ្គុំអោយទៅ។

ខ៖ចា៎ ម៉ែឪផ្សំផ្គុំអោយប៉ុន្តែគេស្រលាញ់ខ្លួនគេ ហើយយើងផ្សំផ្គុំអោយគេទៅ
បើបានកូនស្រីខ្ញុំនេះបានការ ហើយកូនប្រុសនោះអត់បានការទេ ប៉ុន្តែរៀបចំតិចតួច។

ក៖ហើយក៏សែនអីតិចតួចអីអញ្ចឹងទៅ ហើយចុះប្រពន្ធគាត់ឈ្មោះអីគេមីង។

ខ៖ឈ្មោះចាន់ អ៊ីគេទេញ៉ុំអត់ស្គាល់ត្រកូលកូនប្រសារទេ។

ក៖ចុះឈ្មោះគាត់។

ខ៖ឈ្មោះចាន់។

ក៖ឈ្មោះចាន់ គាត់នៅខេត្តណា?

ខ៖ខេត្តព្រៃវែង។

ក៖ចុះកាលគាត់ការជាមួយកូនមីង ចុះឥលូវគាត់នៅណាវិញ?

ខ៖ឥលូវនៅច្បារអំពៅ។

ក៖នៅច្បារអំពៅ គាត់រកស៊ីអីគេដែល។

ខ៖គាត់លក់បន្លែ ប្រពន្ធគេលក់បន្លែនៅច្បារអំពៅទាំងអស់។

ក៖អញ្ចឹងអំ ហើយគាត់មានផ្ទះខ្លួនឯងតើមីង?

ខ៖ជួលគេ។

ក៖ជួលគេនៅច្បារអំពៅហើយលក់បន្លែ ហើយចុះកូនបន្ទាប់មកទៀត។

ខ៖កូនបន្ទាប់មានតែកូនស្រីនេះ។

ក៖កូនស្រីនឹងឈ្មោះអីគេ?

ខ៖ឈ្មោះរេន គន្ធា នឹង!។

ក៖រេន គន្ធា ឥលូវញ៉ុំបកទៅណោះវិញ កូនបងមានកូននៅ។

ខ៖មានកូនស្រីមួយ។

ក៖មានកូនស្រីមួយ កូនគាត់មានឈ្មោះអីគេ។

ខ៖នួន ចាន់ម៉ូលីកា ហៅក្រៅឈ្មោះសុងអ៊ី។

ក៖សុងអ៊ី ហើយគាត់ប្រុសរឺស្រី។

ខ៖ចុះឥលូវគាត់អាយុប៉ុន្មានហើយមីង ៧។៨ឆ្នាំ។

ក៖៧។៨ឆ្នាំ ហើយគាត់មានកូនតែមួយតើអី។

ខ៖ចាំ កូនតែមួយនឹង។

ក៖បាទ! ចុះឥលូវដល់វគ្គកូនស្រី គាត់មានគ្រួសារហើយអញ្ចឹងសុំឈ្មោះគាត់ម្តងទៀតមីង។

ខ៖កូនស្រីឈ្មោះរេត គន្ធា។

ក៖ហើយចុះឆ្នាំនឹងគាត់អាយុប៉ុន្មានហើយមីង។

ខ៖ឥលូវ៣០ឆ្នាំ។

ក៖តែគាត់ការហើយមីងណោះ។ ហើយប្តីគាត់ឈ្មោះអីគេមីង។

ខ៖ឈ្មោះសុខ សិត។

ក៖សុខ សិត។ ហើយគាត់សព្វថ្ងៃគាត់រកស៊ីអីដែល។

ខ៖មិនដឹងមុខរបបរអីគេទេ ធ្វើសំណង់ក៍មិនច្បាស់អីក៍មិនអី ពិបាកដល់ហើយ
មុខរបបរវាមានតែធ្វើសំណង់នឹងមានធ្វើអីទេ។

ក៖អ៎ សំណង់ហើយនៅផ្ទះខ្លួនឯងរឺក៍ម៉េចឥលូវនឹង សព្វថ្ងៃ។

ខ៖ឥលូវនៅជាមួយខ្ញុំ។

ក៖នៅជាមួយមីង គាត់នៅប៉ុន្មានឆ្នាំហើយតាំងពីគាត់ការមក។

កូនគាត់៖តាំងពីការហើយមកនៅភ្លៀមនឹង។

ខ៖តាំងពីការហើយ៥។៦ឆ្នាំហើយ។ ការតាំងពី២០១០ អញ្ចឹង៨ឆ្នាំ
កាលការអត់ការនៅទីនេះទេ ការនៅសំរោងធំអ៎ ជិតអ្នកលឿងអ៎។

ក៖ហើយចុះកាលការមុខការធ្វើម៉េចបានប្តីគាត់ជួបជាមួយគាត់។

ខ៖ទេគេទៅដើរលេង មានពួកមាក់គេអ្នកនាំ។

ក៖អ៎ មានពួកម៉ាក់នាំហើយក៍ពេញចិត្តទៅហើយក៍ការអោយទៅ។

ខ៖ពេលគេឃើញហើយគេស្រលាញ់ គេអោយឪពុកម្តាយមកសួរ មកដណ្តឹងយើងការទៅ។

ក៖ហើយចុះបន្ទាប់មកទៀតមីងសព្វថ្ងៃមីងប្រកបមុខរបបរអីគេមីង។

ខ៖ញុំធ្វើចុងភៅនៅមន្ទូល។

ក៖អ៎ ធ្វើចុងភៅ ហើយធ្វើប៉ុន្មានឆ្នាំហើយមីង។

ខ៖ខ្ញុំធ្វើចុងភៅនឹងវាយូរហើយ
គ្រាន់តែថាវាពិបាកយើងដូរពីកន្លែងមួយទៅកន្លែងមួយអញ្ចឹង
ប៉ុន្តែកន្លែងក្រោយនេះខ្ញុំចូលបានមួយឆ្នាំជាងហើយ។

ក៖មីងចុះមានគិតថាពេលខាងមុខទៀតមីងចង់ប្រកបមុខរបបរអីគេដែល។

ខ៖ខ្ញុំមិនចង់អញ្ចឹងញុំចង់ប្រកបមុខរបបរខ្លួនឯងអញ្ចឹង ប៉ុន្តែយើងអត់មានប្រាក់អី
ថវិការដែលយើងចង់លក់ចងដូរអីអញ្ចឹងយើងអត់មានអញ្ចឹង
បើមានញុំចង់បើកមុខរបបរអីមួយតូចតាចល្មម  លក់អីសំរាប់ខ្លួនយើងចាស់អីអញ្ចឹង
សំរាប់ខ្លួនយើងចាស់នៅផ្ទះយើងអត់ចង់ធ្វើការនៅនេះទៀតតែឥលូវញ៉ុំទាល់ញុំដោះស្រាយ
វាមិនទាន់ចេញ
ដោះអត់បានដល់អញ្ចឹងចេះតែធ្វើអោយគេគតិចៗទៅកំលាំងយើងចាស់ហើយវាមិនដូចយើ
ងពីក្មេងទេ យើងក្មេងយើងអាចលើកឆ្នាំបាយធំៗបាន
ដល់ពេលយើងចាស់ទៅយើងលើកឆ្នាំងបាយអត់រួចទេ

អញ្ចឹងយើងចង់លក់មុខរបបរអីស្រាល់ៗអញ្ចឹង
នៅផ្ទះអីអញ្ចឹងទៅគ្រាន់តែមើលចៅនៅផ្ទះអីអញ្ចឹងតែឥលូវវាមិនទាន់មានលិទ្ធិភាព។

កៈហើយចុះគិតថាមុខរបបរអីដែលមីង បើសិនជាមានលុយមានអីអ្ហ៎ះ។

ខៈបើសិនជាមានលុយញ៉ុំចង់លក់ម្ហូបអាហារអី បាយទឹកអីនៅផ្ទះចង់លក់បាយ
លក់ម្ហូបនៅផ្ទះអីអញ្ចឹង។

កៈមីងចុះកាលពីក្មេងមីងដែលទៅរៀននៅសាលាអត់មីង។

ខៈខ្ញុំរៀនបានថ្នាក់ទី៧ពីសង្គម រៀនដល់ថ្នក់ទី៧ញ៉ុំបែងពីអាពូតទៅ
ញ៉ុំរៀននៅវិទ្យាល័យទួលទំពួងយើងនឹង។

កៈរៀននៅសាលាទួលទំពួល ចុះមតេយ្យទី១។២ មីងរៀននៅណា?

ខៈកាលមតេយ្យ ទី១ ទី២ ញ៉ុំរៀននៅកៀនស្វាយ
ដល់ពេលគេរជិតដល់ភ្នំពេញពេកទៅញ៉ុំក៏រត់ទៅក៏រៀននៅសាលាវិទ្យាល័យទូលទំពូល
ញ៉ុំនៅទូលទំពូលយូរហើយតាំងញ៉ុំអាយុ៦ឆ្នាំមក ឪពុកម្ដាយញ៉ុំនៅនឹងរហូត
ដល់ពេលបែកទៅបែកនៅកំពុងសោមញ៉ុំទៅលេងផ្ទះយីញ៉ុំ តាញ៉ុំនៅកំពុងសោម
ដល់ពេលនឹងបែកពីឪពុកម្ដាយញ៉ុំទាំងអស់ ញ៉ុំទៅនឹងតែម្នាក់ឯងគត់
ពេលដល់នឹងគាត់មានបុណ្យសាក់អញ្ចឹង គេយកគាត់ទៅវៃចោលទៅនៅសល់ញ៉ុំម្នាក់គត់
គាត់ឆ្លើយថាញ៉ុំឈ្នួលគាត់ទេបានខ្ញុំគាត់
បើគាត់ឆ្លើយចៅគាត់ប្រហែលជាគេយកញ៉ុំទៅវៃចោលបាត់ហើយ
គាត់ឆ្លើយថាញ៉ុំឈ្នួលទេបានញ៉ុំនៅរស់ហើយកាលនឹងអាពូតវាស្រឡាញ់ណាស់វណ្ណាក់ក្រៃក្រ
បើថានេះសាក់គិដិភូមិវិញវាអត់ចូលចិត្តទេ
ដល់អញ្ចឹងគាត់ឆ្លើយថាគាត់មិនចង់អោយញ៉ុំនឹងទៅងាប់ជាមួយគាត់ទៅអញ្ចឹងអាញ់
ប្រាប់គេថាអ្នែញថាឈ្នួលអ្នែញ
ទុក្ខអែងទៅជូនម៉ែអែងទៅហើយពេលគាត់ឆ្លើយអញ្ចឹងគេយកគាត់ប្រពន្ធ
កូនគាត់ទៅវៃចោលទៅអស់
គាត់សាក់៥នៅកំពុងសោមយើងនឹងដល់ពេលនេះទៅគេយកទៅវៃចោលទៅ
ហើយអាងៃគេយកទៅវៃចោលញ៉ុំលូង់ទៀត
ពេលប្រលឹមគេមកហៅព្ជួៗគេយកហៅស្លៀកពាក់មកទៅទទួលរដ្ឋមន្ត្រីថាអញ្ចឹងហើយដល់ពេល
ហើយទៅ អញ្ចឹងញ៉ុំក៏សួរគេថាញ៉ុំទៅដែលអត់ទេ
អត់ទេបុត្រនារីឯងទៅរែកដីទៅយកតែព្ជួៗទៅទេហើយតាញ៉ុំគាត់
គាត់ដឹងតាយកគាត់ទៅគេយកទៅវៃចោលហើយថាអញ្ចឹងគាត់ផ្ដាំយីគាត់ថារបបរតាំងប៉ុន្មា
នដួរអោយកូនចៅស៊ីទៅកុំអោយស្គាល់អត់ស្គាល់ក្លៀនគាត់ប្រាប់អញ្ចឹង
ហើយយីញ៉ុំគាត់យំគាត់ថាអាញ់ផ្ដាំមួយទៀតបើសិនជាល្ងាចអាញមកផ្ទះវិញនឹងជីវិតអាញរស់បើ
កាលណាអាញបាត់ពីល្ងាចនេះទៅឯងកុំសង្ឃមអាញងាប់ហើយ
គាត់ប្រាប់យើងអញ្ចឹងហើយមែនបាត់គាត់តាំងពីនឹងរហូតដល់ឥលូវដល់ពេលជិតបែកហើយ
គេយកយើងទៅវៃចោលទៀតអស់អាលិញនៅសល់តែញ៉ុំនាក់ឯងគត់ដល់ពេលញ៉ុំមកវិញញ៉ុំមក
តាមគេតើបែកអាពូតហើយញ៉ុំមកតាគេនឹងមករៀវរកឪពុកម្ដាយញ៉ុំដល់រទោះភ្លើងជាម
កញ៉ុំមកតាមគេមកដើររកឪពុកពេញភ្នំពេញនឹងដល់ពេលឪពុកញ៉ុំគាត់ស្រូតដល់ភ្នំពេ
ញមករកញ៉ុំអញ្ចឹងដែលបានមកជួបគ្នានៅភ្នំពេញវិញទៅបានរស់មានតែឯងមួយគាត់បង
ប្អូន៧;
៨នាក់គិតទៅគាត់ស្លាប់អស់៧នាក់ស្លាប់តាំងកូនតាំងចៅប្ដីប្រពន្ធគាត់នៅសល់តែញ៉ុំនាក់ឯ
ងដោយសារតែគាត់ឆ្លើយថាញ៉ុំឈ្នួលគាត់ បើឆ្លើយថាកូនចៅនឹងទៅទាំងអស់

កាលនឹងគាត់ប្រាប់ញុំដែលដល់
ពេលនឹងញុំហត់ពេកអត់ហូនបាយជាមួយគាត់ទេអោយគាត់ពិសារមុខហើយគាត់ថាកុំធ្វើអញ្ចឹងតាកាលណាធ្វើអញ្ចឹងអាញថាអ្នែងឈ្លួលអាញហើយអញ្ចឹងស៊ីអីស៊ីចូលគ្នាទៅហើយដើរចេញទៅហើយមែនហើយគេយកឃីញុំទៅវៃចោលតើវៃចោលអស់អាជិតបែកភ្នំពេញហើយនៅសល់តែមួយខែពីរខែអីគេយកវៃចោលអស់មានអីណាញុំឡើងដល់កងចាឡាត់ទៅតែម្នាក់ឯងគត់
ពេលមកវិញគេយកឃីយកតាប្អូនអាតូចៗអីគេយកវៃចោលអស់នៅតែញុំម្នាក់ឯងបែកមកវិញមកវិញម្នាក់ឯងគត់ហើយទៅពីនេះទៅ៨នាក់។

ក៖ទៅ៨នាក់នឹងពីណាខ្លះមីង។

ខ៖ចាំមើលកូនគាត់៦សុទ្ធតែកូនប្រុស អាធំៗរៀនថ្នាក់ទី៣ ទី៤ហើយអាតូចៗបីនឹងដៃ១
អាចេះដើរមួយ ហើយគាត់ពីរនាក់ទៀត។

ក៖សុទ្ធតែកូនចៅគាត់មែន។

ខ៖សុទ្ធតែកូនគាត់បង្កើត។

ក៖អញ្ចឹងមានចាំឈ្មោះគាត់អត់។

ខ៖គាត់ឈ្មោះខៀវ ស៊ីផង់។

ក៖ចុះកូនបងមីង?

ខ៖កូនបងមិនដឹងឈ្មោះអីខ្លះទេព្រោះយូរហើយស្គាល់ឈ្មោះសាត់ស្សា ហើយនឹងជំពូ។

ក៖គាត់ត្រូវជាម៉េច?

ខ៖គាត់ត្រូវជាកូនរបស់តាខ្ញុំនឹង។សាត់ស្សា នឹង ជំពូធំៗអត់ហើយ
ហើយតូចៗប៉ុន្មាននាក់ទៀតញុំភ្លេចឈ្មោះអត់ហើយ។

ក៖អញ្ចឹងសុទ្ធតែគេយកវៃចោលអស់។

ខ៖គេយកវៃចោលអស់ហើយម៉ាសំបុកនឹង។

ក៖អញ្ចឹងចុះមីងកាលជំនាន់អាពូតនឹងគេអោយមីងធ្វើអីដែល។

ខ៖រែកដី កាលនឹងញុំឆ្លាតញុំអត់សូវរែកដីព្រោះញុំចេះវិចខ្សែបង្គី ចេះត្បាញបង្គីអីអញ្ចឹង
ដល់ពេលអញ្ចឹងគេអោយយើងទៅកាប់អាសិ
អ្នកណារែកដីអញ្ចឹងទៅហូបបបបរទៅអ្នកណាវិចខ្សែរបង្គីគេវិចបាយទៅរក
នឹងហើយទៅមកវិញលីអាសិ១០ដើមៗមកជូនកាលដើទៅកាប់អាខ្លែងភ្លាល់យើងនឹងដំអាធ្វើខ្សែបង្គីវិញធ្វើខ្សែរបង្គីអីអញ្ចឹងណាស់ បានចេះអញ្ចឹងបានធូរញុំអត់សូវរែកដីទេ
បើសិនជាអ្នកអត់ចេះអញ្ចឹងគេរែកដីងាប់
ម្ស៉ៗរែកងាប់ដូចញុំអញ្ចឹងម៉ាអាទិត្យរឺម៉ាខែត្រូវទៅកាប់អាសិម្តង ម៉ាអាទិត្យទៅកាប់
ម៉ាអាទិត្យក្រោយវិញខ្សែរបង្គីអីនៅរោងអៅអញ្ចឹងទៅ
យើងអត់សូវហត់ទេដល់ពេលអត់ចេះអញ្ចឹងហត់ណាស់។

ក៖ហើយចុះមីងដល់ពេលធ្វើអាកិច្ចការនឹងអស់ហើយគេយកអាទាំងអស់នឹងយកទៅយកនៅណាមីងមានដឹងអត់។

ខ៖អត់លក់ទេគេចែកតាមក្រុមរែក។

កៈចែកតាមក្រុមវិញ។

ខៈចាំ ពេលធ្វើហើយអញ្ចឹងទៅក្រុមណាក្រុមនឹងធ្វើក្នុងអាកងមាន១៥០នាក់
អញ្ចឹងគេចាត់៥;៦ដើរទៅកាប់អាសី កាប់អាខ្លែងភ្លាល់យកទៅវិញខ្សែរបង្គីអីអញ្ចឹងណាស់
ពេលវិញគេចែកទៅតាមខ្សែរបង្គីណាខ្លី រីវែងដាច់អោអញ្ចឹងទៅយើងដូរអោយគេ
តាមក្រុមគេទៅដូរហើយយើងទៅជួយរែកដីគេទៅនឹងអញ្ចឹង
មិនមែនយើងហើយនៅម៉ានកន្លែងអីអត់បានទេ។

កៈចុះមីងកូនចៅរបស់កុងគាត់ធ្វើអីគេកាលជំនាន់នឹង។

ខៈនិយាយទៅម៉ាគ្រួសារចេះអញ្ចឹងទាំងអស់
វាទៅតាមអញ្ចេកក្មេង៨ឆ្នាំគៀរគោព្រឹកឡើងទៅរៀន
ចេញពីរៀនមកកាប់កន្ទ្រៀងខែតធ្វើជី កាប់អាចយ៍គោចាក់ស្រែធ្វើជី
ពេលថ្ងៃល្ងាចឡើងយើងគៀរគោទៅ
ស្រីៗណាទៅគៀរគោបានទៅៗស្រីណាទៅកាប់កន្ទៀងខែតបានទៅៗ
ពេលព្រឹករៀនពេលថ្ងៃឡើងដើរគៀរគោហើយដឹងគោអោយស៊ីស្មៅស៊ីអីអញ្ចឹងទៅ។

កៈចុះជំនាន់នឹងមានរៀនដែលមែន។

ខៈរៀនអោយរៀនចាំ
រៀននឹងមានរៀនស្អីទេរៀនពីមាគ៌ារបស់គេបដិវត្តរៀនស្អីគេមិនអោយរៀនអីអង្គការអញ្ចេក
អញ្ចោះអី  គេបង្រៀនពីអង្គការមិនដែលរៀនអក្សរអីអោយចេះទេ
អោយចេះដែលចេះអក្សរតិចតួចមិនចេះអក្សរជ្រៅជោះទេ។

កៈបាទ! ចុះពេលមីងរៀននៅសាលាទូលទំពួង ពេលនឹងមីងបានរៀនថ្នាក់ទី៧ដែល
ចុះសព្វថ្ងៃនេះមីងនៅចេះអក្សរខ្មែរចេះអានចេះអីដែលតើមីង។

ខៈចេះនៅចាំនៅឡើងទេ។

កៈបាទ ហើយចុះមីងបានជាឈប់រៀននៅថ្នាក់ទី៧។

ខៈបែកអាពូតទៅគេជំលាស់យើងចេះទៅតាមនេះ កាលនឹងបែកអាពូត។
បើសិនជាកុំបែកអាពូតរៀនច្រើនដែលគេបែកអាពូតទៅញុំឈប់ទៅ
ហើយកាលនឹងមិនសូវជារៀនបានប៉ុន្នានទេគ្រាប់ផ្លោងរៀនឈប់រៀនឈប់នឹងគ្រាប់ផ្លោងចូ
លភ្នំពេញច្រើនពេកទៅវារៀនបានតែប៉ុន្នានមិនសូវរៀនបានជាប់ទេ
ឪពុកថាកុំទៅរៀនពេកពេលគ្រាប់ផ្លោងក្រែងធ្លាក់ចូលសាលាកន្លែងអីងាប់អីអញ្ចឹងណាស់
ឈប់ជាងមួយឆ្នាំដែលហើយទៅបែកភ្នំពេញទៅ។

កៈចុះមីងចេះអក្សរអីក្រៅពីអក្សរខ្មែរនឹងអត់? ចង់ថាមានចេះជប៉ុនចេះអីផ្សេងពីនឹងអត់?

ខៈអត់ទេកាលជំនាន់នឹងគេអោយរៀនបារាំងទេ មិនអោយរៀនខ្មែរទេណ៎នែ
មិនអោយរៀនអងគ្លេសអីទេរៀនអីបារាំងចេះបារាំងចាំ
ប៉ុនឥលូវញុំមើលដាច់បានខ្លះៗដូចចង់ភ្លេចអស់ហើយ។ ខានប្រើយូរហើយ
ប៉ុន្តែបើគេសរសេដាក់អីអញ្ចឹងមកញុំមើលបានអានេះគេថាមិញ
ដល់ពេលឥលូវគេនិយមអងគ្លេសច្រើនដូចថាឥលូវគេសរសេរឡែបជំនាន់អាញគេមិនហៅឡែ
បទេគេហៅឡារ មែនទេ។

កៈបាទ
ហើយចុះឥលូវនេះមីងនៅតែចេះអក្សរខ្មែរតែមួយមុខគត់រឺក៏មិចរៀនចេះអីពីអក្សរខ្មែរអត់។

ខ៖អត់ចេះទេចេះតែខ្មែរ អត់មានចេះអីទេចេះតែខ្មែរ។

ក៖ហើយចុះមីងមានចេះជំនាញអីគេដែលរហូតដល់ឥលូវពីមុខដល់ឥលូវមីងមានចេះជំនាញអីគេអត់ ឧទាហរណ៍ថា ដេប៉ាក់ផ្សេងៗអីអញ្ចឹងណាស់។

ខ៖ពីមុខញ៉ុំចេះចាក់អាវចាក់ខោ
កាលជំនាន់នឹងគេរៀនម្ហូលពីរនឹងហើយដល់ពេលឥលូវបាត់អាម្ហូលពីរនឹងលែងឃើញមានសោះ
ឥលូវយើងចាស់ហើយវាមិនដូចកាលយើងនៅពីក្មេងទេចាស់ហើយមើលមិនសូវឃើញសំឡឹងយូរបែកផ្សែង ឥលូវលេងហើយដាក់អានឹងបានជាចាប់អាជីពចុងភៅជាប់រហូត។

ក៖មីងកាលមីងធ្វើជំនាញមួយនឹងអ្ហះ
មីងធ្វើហើយយកទៅលក់នៅទៅផ្សារខ្លួនឯងរឺក៏មានម៉ូយជាមកទិញ។

ខ៖មានម៉ូល
កាលពីជំនាន់លុនណុលនឹងគេធ្វើអាកន្សែងដៃយើងនឹងសរកូនកន្សែងតូចៗនឹងគេមានចាក់គេចាក់ហើយគេមានហូតជាយអញ្ចឹងហើយញ៉ុំចាក់អាកន្សែងនឹងបោះយកអោយទៅផ្សារ។
កាលនឹងយើងទៅណាក៏មិនរួចដែលបោះអាកន្សែងទៅ
គេលក់មួយ១០០០តែយើងបោះអោយគេមួយ៥០០ទេ ១០បាន៥០០០អីអញ្ចឹងណាស់
កាលជំនាន់នឹងវាមិនបានថ្លៃផង។

ក៖ហើយចុះមីងមានចេះអីក្រៅពីដេអត់។

ខ៖អត់តេក្រៅពីនឹងមានតែចុងភៅនឹងទេ។

ក៖ចុះមីងរៀនធ្វើចុងភៅពីណារឺក៏ម៉េច។

ខ៖ចុងភៅនឹងញ៉ុំរៀនពីបងញ៉ុំ បងញ៉ុំចេះចុងភៅ
បងញ៉ុំគាត់បោយបារាំងគាត់បង្រៀនញ៉ុំហើយញ៉ុំចេះពីគាត់មកគាត់ចុងភៅបារាំង។

ក៖គាត់ទៅរៀននៅណាដែលកាលនឹង។

ខ៖មិនដឹងគាត់ចេះពីណាដែលញ៉ុំអត់ដឹងដែល
ញ៉ុំគ្រាន់តែដឹងថាគាត់ចុងភៅរបស់បារាំងអញ្ចឹង ភាសាពីមុខគេហៅថាបោយបារាំង
ដល់ពេលនេះគេហៅថាចុងភៅបារាំង។

ក៖ឥលូវមីងចេះតែស្លរ ហើយភាគច្រើនស្លម្ហូបអីគេមីង។

ខ៖មិនទៀងជូនកាលគេត្រូវការអីផ្សេងៗគេហៅយើងទៅ
ទៅតុការគេហៅអីយើងធ្វើនឹងទៅយើងបានចំណេះពីនឹងដែល
ញ៉ុំច្រើនតែដើរជាមួយតុការបានញ៉ុំចេះច្រើន។

ក៖ចុះពេលដែលមីងដើរជាមួយតុការមីងស្គាល់ចុងភៅការមែន។

ខ៖ចាំ
ស្គាល់ចុងភៅការគេរាប់រានញ៉ុំអញ្ចឹងគេស្គាល់ញ៉ុំដល់ពេលណាញ៉ុំធ្វើម្ហូបឆ្ងាញ់អញ្ចឹងគេហៅញ៉ុំទៅចាំ មានជូនកាលមានគេហៅញ៉ុំធ្វើក្រៅ៤
១០តុអីអញ្ចឹងញ៉ុំអាចធ្វើក្រៅតែពីបីនាក់បានចាំ។

ក៖ចុះអីចូលចិត្តម្ហូបអីគេដែលមីងចង់ធ្វើចង់ញ៉ុំខ្លួនឯងអ្ហុះម្ហូបអីគេដែលមីង?

ខៈបើម្ហូបរាល់ថ្ងៃញុំចូលចិត្តសម្លម្ជូគ្រឿង
ពីមុខគេមិនដែលមានតុងយាំអីគេនឹងម្ហូតលូវវាថ្មីច្រើនគេបង្ហោះតាម។។។។អញ្ចឹងហើយយើងអាចយកដំរិសពីនឹងមកក៏បានចាំ
គេបង្ហោះមកម្ហូបថ្មីអញ្ចឹងណាស់ចាំម្ហូនបនេះម្ហូបនោះអីអញ្ចឹងទៅ
រៀនតាមតុការគេមានច្រើនមុខដែល។

កៈអញ្ចឹងចង់សួរមីញថាអញ្ចេកកាលមីងនៅពីក្មេង
មីងធ្លាប់មានក្ដីស្រមៃថាមីងចង់ធ្វើអីគេអត់
កាលអត់ទាន់បែកអាពូតអីកាលនៅរៀនអីអូះ។

ខៈកាលនៅរៀនក្ដីស្រមៃញុំថាធ្វើការតែមួយមុខទេ។

កៈការងារអីគេដែលមីង។

ខៈកាលពីបែកអាពូតមកញុំធ្វើការនៅក្រសួងការបរទេសអាខាងក្នុងនឹងក្រៅប្រទេសយើងនឹង
ញុំធ្វើនៅកន្លែងនឹងដល់ពេលញុំឆ្លួស់គ្នាជាមួយប្តីញុំទៅញុំឈប់ធ្វើការនៅនឹងទៅឈប់រហូតទៅបែកអាពូតមកញុំធ្វើការនៅកន្លែងនឹង។

កៈប្រហែលជាប៉ុន្មានឆ្នាំដែល?

ខៈញុំធ្វើ៥៦ឆ្នាំដែល។

កៈអំ យូរដែលហើយ។

ខៈញុំធ្វើការនៅនឹងដល់ពេលញុំឈ្លួសគ្នាជាមួយប្តីញុំ
ញុំលែងគ្នាតាំងពីមុខមករហូតដល់តលូវនឹងទៅ
ហើយញុំដើរមកជីវិតញុំអស់ច្រើនណាស់ទៅធ្វើអាណាម័យសាលាផងច្រើនណាស់ទំនាំតែបានសព្វថ្ងៃញុំជួបសព្វបែកយ៉ាងចិញ្ចឹមកូនយើងស្រីមេម៉ាយ
យើងតស៊ូគ្រប់បែបយ៉ាងទាំងអស់លក់ដូរ ទៅតាមខែតាមរដូវដល់ខែលក់ពោត
លក់លៀសដើម្បីចិញ្ចឹមកូនតស្ហូរគ្រប់បែបយ៉ាងអស់ចិញ្ចឹងកូន២អ្នកឯងហើយយើងអញ្ចឹងមានតែដូរទៅតាមរដូវខែផ្លែឈើ  ផ្លែសៅមៅ  ផ្លែធូរេន
ដល់ពេលតលូវញុំចាស់ទៅញុំឡើងដាក់ទៅវាមិនរួច
ញុំចាប់អាជីពខ្លាំងជាងគេគឺចុងភៅនឹងម៉ង
ចុងភៅវាស្រាលហើយញុំធ្វើចុងភៅនៅមណ្ឌលកន្លែងនេះញុំមិនអីធ្ងុនធ្ងរអីទេចាននឆ្នាំគេអ្នកលេង
បើក្មេងលេងញុំដឹងតែធ្វើម្ហូបឆ្អិនពួកវាលើកមកយើងដូសអោយពួកវាទៅហើយរាល់ថ្ងៃអញ្ចឹងបើថាលើកអីធ្ងុនធ្ងូលើកមិនរួចទេ។

កៈបាទ
ហើយចុះធ្វើម្ហូមអោយគេនឹងជាលក្ខណៈប៉ុន្មាននាក់ដែលមីងសំរាប់តម្រូវគ្នាប៉ុន្មាននាក់។

ខៈតម្រូវគ្នា៣០នាក់។

កៈកូនក្មេងរឺក៏មនុស្សចាស់។

ខៈចាស់ក្មេង ៣០នាក់។

កៈហើយចុះញុំចង់និយាយមីងពិបាកឡីម្ហូបអត់។

ខះមុខដំបូងពិបាកដល់ពេលយូរទៅលេងអត់មានពិបាកទេចាំ
សាំមរាល់ថ្ងៃទៅមិនពិបាកអីទេព្រោះក្មេងក៏វាអត់អោយយើងលំបាកដែលពេលមានការអីពិបាកទៅវាជួយយើងដែលនឹងចាំ
ជួយយើងគ្រប់បែបយ៉ាងទាំងអស់ពេលយើងមកពីផ្សារយើងដាក់ពុកវាជួយយើងខ្លះចិតបន្លែខ្លះលៀងសាច់ទៅ ខ្លះលៀងត្រីអីអញ្ចឹងទៅ  ចាំញុំធ្វើកន្លែងនឹងជាប់បានយូរដោយសារអញ្ចឹងបើក្រៅពីនឹងនៅជាប់មិនបានយូរដោយសារបើធ្វើធម្មតាទាល់តែមានអ្នកជួយ
នៅនេះបានក្មេងៗជួយ។

កះចុះមីងកាលមីងរៀបការជាមួយប្តីមីងអ្នំា ស្គាល់គាត់តាមរយះអីគេមីង។

ខះស្គាល់គាត់រយះកាលនឹងធ្វើការជាមួយគ្នា។

កះធ្វើការជាមួយគ្នា ហើយចុះបានម៉ែឪផ្សំផ្គុំអត់។

ខះចាំ។

កះហើយចុះមីងម៉ែឪពុកខាងប្តីអត់។

ខះអំ
អត់ស្គាល់ទេព្រោះឪពុកម្តាយគាត់អាពូតសំលាប់ចោលអស់ហើយគាត់មានតែបង។គាត់មាន៣រឺ៤នាក់បងប្អូន។

កះចុះកាលមីងនៅពីក្មេងមីងចងចាំអនុស្សាវរីយ៍អីខ្លះជាមួយនឹងមិត្តភក្តហ៉ាមីង។

ខះពួកមិត្តភក្តមានតែធ្លាប់ធ្វើការជាមួយគ្នា។

កះចុះកាលនឹងមីងមានមិត្តភក្តជុំគ្នាអត់គាត់ឈ្មោះអីដែលមីងមានចាំអត់។

ខះមិត្តភក្តជិតស្និទស្លាប់អស់ហើយ។

កះដឹងហើយមីងមានចាំឈ្មោះគាត់អត់។

ខះនៅរាល់ងថ្ងៃលក់ចេកនៅច្បារអំពៅ។

កះគាត់ឈ្មោះអីគេមីង។

ខះឈ្មោះឌី។

កះឈ្មោះឌីមិត្តភក្តជិតស្និទម៉ង។

ខះចាំមិត្តភក្តជិតស្និតនៅតែមួយទេ កាលនឹងម៉ាជំនាន់នឹងងាប់ដោយសារអេដស៍អស់ហើយ
នេះដោយសារញុំមេម៉ែកុំអីបែបទៅនឹងគេដែល
ដោយសារញុំមេម៉ាយអត់ប្តីបិសអីទៅនិងគេដែលមិត្តភក្តជិតស្និតនៅរាល់ថ្ងៃនឹងក៏វាមេម៉ាយដែលបើសិនវាមានប្តីវិញក៏វាទៅដែល
យើងនិយាយគ្នាថាសំណាងហើយអត់នៅមេម៉ាយបើយើងមានប្តីបិសអីទៅនឹងគេដែល
មានមិត្តភក្តច្រើនតែវាងាប់អត់ហើយដោយសារអេដស៍ចាំ។

កះហើយអញ្ចឹងចុះដូចជាមីងហើយនឹងពូដោយសារតែអត់ត្រូវរៅគ្នាណោះមីងណោះ។កាលនឹងមីងការជាមួយពូនៅណាមីង នៅខេត្តណាដែល។

ខះញុំការនៅកៀនស្វាយយើងនឹង។

កៈបាទ ការនៅកៀនស្វាយ ហើយបន្ទាប់មកមីងបែកផ្ទះជាមួយម៉ាយមីងមែន។

ខៈបែកផ្ទះនៅជាមួយបង ហើយចេញពីបងទៅបាននៅផ្សារកណ្ដាលយើងនឹង
នៅជាមួយប្ដីធ្វើការនៅទាំងអស់គ្នា។

កៈហើយចុះបងឈ្មោះអីគេមីង បងបង្កើតរីក៍បងជីដូនមួយរឺយ៉ាងម៉េច។

ខៈបងនិងបងបង្កើតឈ្មោះយេង
ស្លាប់បាត់ហើយគាត់ចាស់គាត់ស្លាប់ហើយគាត់អាយុ៧០ជាងប្រហែល៤។៥ឆ្នាំហើយ។

កៈអញ្ចឹងញុំ
ការសំភាសន៍នេះមានតែប៉ុណ្ណឹងហើយខ្ញុំសូមយកសំលេងនេះទៅចាក់ផ្សារនៅក្នុងគេហទំព័ររបស់សាកលវិទ្យាល័យBYUដោយយកសំលេងមួយទៅចាក់ផ្សារដើម្បីអោយក្មេងជំនាន់ក្រោយៗទៀតដើម្បីគាត់បានយល់ថាតើមីងជួបបញ្ហាលំបាកអីគេខ្លះនៅក្នុងជីវិតហើយមីងជួបបញ្ហាអីគេខ្លះមានជំនាញអីគេខ្លះហើយមីងជួបទុក្ខលំបាកអីគេខ្លះអញ្ចឹងញុំសុំអោយមីងផ្ដល់ជាលក្ខណះអនុសាសន៍មួយដើម្បីអោយក្មេងជំនាន់ក្រោយអោយគាត់ខិតខំរៀនសូត្រអោយគាត់ដើរតាមផ្លូវល្អកុំអោយគាត់កិចរេសពីសាលាអីអញ្ចឹងមីងអញ្ចឹងសូមដផ្ដល់យោបលចុះមីង។

ខៈចង់ផ្ដាំទៅក្មួយៗជំនាន់ក្រោយដែលអោយយើងខំប្រឹងរៀនទៅចំនេះទាំងអស់នេះវាគ្មានបាត់បង់សាបសូន្យទេកាលណាយើងរៀនចេះដឹងទៅមានអនាគត់វែងឆ្ងាយខ្ពង់ខ្ពស់បើសិនជាយើងមិនខំប្រឹងរៀនទេមិនចេះអក្សរទេមិនអាចធ្វើការងារអីបានខ្ពង់ខ្ពស់ដូចគេអញ្ចឹងកាលណាយើងរៀនបានខ្ពង់ខ្ពស់ទៅក៍វាធូរដែលយើងរៀនចេះដឹងទៅបានការងារល្អទៅបើសិនដូចជាកូនខ្ញុំអីរៀនមិនបានដូចគេដល់ពេលខ្លួនចាស់ទៅបាននឹងឃើញស្ដាយក្រោយស្ដាយក្រោយថាម៉ែអាញអោយទៅរៀនបើសិនជាខំរៀនធ្វើការអីធំដុំអីនឹងគេអញ្ចឹងណាស់ម៉ែអោយទៅរៀនតើមិនមែនម៉ែមិនអោយទៅណាប៉ុន្តែមកពីគំនិតកូនទេកូនមិនខំប្រឹងដល់ពេលអញ្ចឹងធ្លាក់ទៅលក់បន្លែអីអញ្ចឹងចុះបើរៀនទៅមានមុខមានមាត់មិនបានការងារធំដុំនឹងគេវាមិនស្រួលខ្លួន។

កៈនិងហើយដល់អញ្ចឹងស្ដាយក្រោយ។

ខៈស្ដាយក្រោយដល់ពេលនេះខ្លួនយើងចាស់យើង
ដល់ពេលចាស់យើងជ្រុលហួសម៉ោហួសពេលហើយអញ្ចឹងបានផ្ដាំអោយក្មួយជំនាន់ក្រោយខំប្រឹងរៀនទៅគំរេសវិជ្ជាអស់នឹងមិនសាបសូន្យទេយើងចេះដឹងញុំមានប៉ុណ្ណឹង។

កៈបាត! អញ្ចឹងអស់គុណច្រើនមីង។